គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee for Cambodia
Comité de Coopération Pour le Cambodge

**ទស្សនវិស័យ:** ការអភិវឌ្ឍប្រកបដោយនិរន្តរភាពសម្រាប់ប្រទេសកម្ពុជា
**Vision:** Sustainable development for Cambodia

# លិខិតចំហ
# ជូនចំពោះដៃគូអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជា
# ស្តីពីការគ្រប់គ្រងការប្រឈមនានាឆ្លើយតបនឹងវិបត្តិនៃជំងឺកូវីដ ១៩ (Covid-19)

**គោរពជូន លោក/លោកស្រី តំណាងដៃគូអភិវឌ្ឍនៅកម្ពុជា**

យើងខ្ញុំសរសេរលិខិតនេះតំណាងឲ្យអង្គការសង្គមស៊ីវិលប្រមាណជាង ៥០០ ស្ថាប័ននៅក្នុងប្រទេស កម្ពុជាដែលជាសមាជិកនៃអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) បណ្តាញអង្គការសង្គម ស៊ីវិលថ្នាក់ខេត្ត និងអង្គការសហគមន៍មូលដ្ឋាននៅទូទាំងប្រទេសកម្ពុជា ដោយសារទេរចំពោះការប្តេជ្ញាចិត្តរបស់ លោក/លោកស្រី ដើម្បីប្រយុទ្ធប្រឆាំងនឹងការរាតត្បាតនៃជំងឺកូវីដ ១៩ ជាសកល ។

យើងខ្ញុំ បានទទួលការលើកទឹកចិត្ត តាមរយៈមត្តទេសភាពរបស់ លោក/លោកស្រី ចំពោះការគាំទ្រអង្គការសង្គមស៊ីវិល និង រដ្ឋាភិបាលកម្ពុជា ដើម្បីដោះស្រាយប្រកបដោយប្រសិទ្ធិភាពឆ្លើយតបនឹងវិបត្តិជំងឺកូវីដ ១៩ ដែលបាន នឹងកំពុងកើតឡើងក្នុងរយៈពេលជាងពីរ (០២) ខែមកនេះ ។ យើងខ្ញុំជឿជាក់ថា ប្រទេសរបស់ លោក/លោកស្រី ក៏បានបង្ហាញនូវបទពិសោធន៍ជាគំរូលើវិធីសាស្ត្រឆ្លើយតបប្រកបដោយប្រសិទ្ធិភាព លើការរាតត្បាតនៃជំងឺកូវីដ ១៩ ដោយគោរពសិទ្ធិមនុស្ស និងគោលការណ៍ប្រជាធិបតេយ្យ ។

ក្នុងកាលៈទេសៈនៃវិបត្តិសកល តួយ៉ាងដូចការរាតត្បាតនៃជំងឺកូវីដ ១៩ នេះ ជំនឿទុកចិត្តពីសាធារណៈជន និងភាពជាដៃគូររវាងសង្គមស៊ីវិល និង ដៃគូអភិវឌ្ឍនានា គឺមានសារៈសំខាន់ក្នុងការលើកកម្ពស់ការគ្រប់គ្រងជំនួយអភិវឌ្ឍន៍បរទេស (ODA) ប្រកបដោយប្រសិទ្ធិភាពដើម្បីឆ្លើយតបនឹងផលប៉ះពាល់ធ្ងន់ធ្ងរផ្នែកសេដ្ឋកិច្ច សង្គម ស្ថាប័ន និងវិធានការរបស់រដ្ឋាភិបាលក្នុងការដោះស្រាយវិបត្តិកូវីដ ១៩ ។

តាមរយៈការធ្វើការពិគ្រោះយោបល់តាមបណ្ដាញអេឡិចត្រូនិច ជាច្រើនលើកជាមួយនឹងសមាជិកនៃអង្គការ គ.ស.ក បណ្ដាញអង្គការសង្គមស៊ីវិលថ្នាក់ខេត្ត និងអង្គការសហគមន៍មូលដ្ឋាន ក៏ដូចជាការធ្វើការស្ទង់មតិដែលសម្របសម្រួលដោយអង្គការ គ.ស.ក ស្ដីពីផលប៉ះពាល់នៃជំងឺកូវីដ ១៩ (Covid-19) លើអង្គការសង្គមស៊ីវិល យើងបានរកឃើញថាអង្គការសង្គមស៊ីវិលបានពន្យារពេលការអនុវត្តកម្មវិធីរបស់ខ្លួន និងមានភាពបត់បែនតិចតួចក្នុងការប្រើប្រាស់ថវិកាដែលមានស្រាប់ដើម្បីឆ្លើយតបនឹងវិបត្តិនេះ ។ ក្នុងពេលជាមួយគ្នានេះ អង្គការសង្គមស៊ីវិលជាច្រើនទទួលរងសម្ពាធបន្ថែមលើការធ្វើអនុទ្យោមភាពផ្នែកច្បាប់ ពាក់ព័ន្ធនឹងច្បាប់ស្ដីពីសារពើពន្ធ ច្បាប់ស្ដីពីការងារ ហើយ សហគមន៍ និងក្រុមគោលដៅ ឬបុគ្គល មួយចំនួនមានតម្រូវឲ្យមានការគាំទ្រខ្ពស់ ខណៈពេលដែលពួកគេកំពុងតែប្រឈមនឹងបញ្ហាសេដ្ឋកិច្ច សង្គម ដោយសារតែការបាត់បង់ការងារ ដែលការណ៍នេះនឹងជះឥទ្ធិពលដល់ប្រជាពលរដ្ឋកម្ពុជា និងក្រុមគ្រួសារពួកគេ ប្រមាណជា មួយលាន(០១លាន)នាក់ ។

ក្នុងទិដ្ឋភាពបែបនេះ យើងខ្ញុំ សូមស្នើដល់លោក/លោកស្រីដែលជាគណៈគ្រប់គ្រងជំនួយអភិវឌ្ឍន៍បរទេសសម្រាប់ប្រទេសកម្ពុជា និងស្នើរដល់រដ្ឋាភិបាលរបស់ លោក/លោកស្រីដូចខាងក្រោម៖

១. សូមបង្កើនជំនួយអភិវឌ្ឍន៍បរទេស និងជំនួយមនុស្សធម៌ដទៃទៀត ដើម្បីជួយដល់រដ្ឋាភិបាលកម្ពុជា និងអង្គការសង្គមស៊ីវិល និងបុគ្គលនានា ដែលធ្វើការប្រយុទ្ធប្រឆាំងនឹងការរាតត្បាតនៃជំងឺកូវីដ ១៩ (Covid-19) ដោយធានានូវការគោរពមូលដ្ឋានសិទ្ធិមនុស្ស និងគោលការណ៍ប្រជាធិបតេយ្យ ។

២. សូមបង្កើនការគាំទ្រផ្នែកស្មារតី នយោបាយ និងហិរញ្ញវត្ថុដើម្បីលើកកម្ពស់ ធានាលំហសង្គមស៊ីវិល និងពង្រឹងតួនាទីរបស់អង្គការសង្គមស៊ីវិលក្នុងការដោះស្រាយនូវផលប៉ះពាល់ធ្ងន់ធ្ងរនានាដែលបង្កឡើងដោយការរាតត្បាតនៃជំងឺកូវីដ ១៩ (Covid-19) ។

៣. សូមចាត់វិធានការសំខាន់ៗនានា ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីផ្ដល់លទ្ធភាពដល់អង្គការសង្គមស៊ីវិលអាចធ្វើប្រតិបត្តិការនៅតាមមូលដ្ឋាន ។ ប្រតិបត្តិការសកម្មភាពទាំងនោះរួមមាន ការផ្លាស់ប្តូរទិសដៅថវិកាដែលមានស្រាប់ និង/ឬ ផ្ដល់ភាពបត់បែនក្នុងការប្រើប្រាស់ថវិកាដល់ដៃគូនានាដែលការណ៍នេះនឹងធ្វើឲ្យពួកគេអាចឆ្លើយតបបានទាន់ពេលវេលានឹងវិបត្តិនៃជំងឺកូវីដ ១៩ (Covid-19) នេះ ។ បន្ថែមពីលើនេះ ដៃគូអភិវឌ្ឍន៍ក៏ត្រូវរួមបញ្ចូលផងដែរ នូវការអនុញ្ញាតិឲ្យពន្យារពេលលើការគ្មានចំណាយចំពោះការធ្វើសកម្មភាព និង ប្រសិនជាអាច សូមបន្ថែមថវិកាដល់ដៃគូខ្លួនដើម្បីឆ្លើយតបតាមតម្រូវការនៃភាពងាយរងគ្រោះបំផុត ក្នុងកំឡុងពេលនៃការធ្លាក់ចុះសេដ្ឋកិច្ច និងវិបត្តិនានានៅក្នុងប្រទេសកម្ពុជា ។

៤. សូមលើកកម្ពស់ និងគាំទ្រការផ្តួចផ្ដើម និងការផលិតក្នុងស្រុក តាមរយៈការពង្រឹងការអភិវឌ្ឍសមត្ថភាពឱ្យកាន់តែល្អប្រសើរឡើង ការផ្លាស់ប្តូរបច្ចេកវិទ្យា និងការលើកលែងពន្ធនាំចូល សម្រាប់ការផលិត

ក្នុងស្រុក ដើម្បីឲ្យបងប្អូនប្រជាពលរដ្ឋខ្មែរមានការងារធ្វើ សម្រាប់គាំទ្រជីវភាពរស់នៅប្រចាំថ្ងៃ រស់នៅដោយសេចក្តីថ្លៃថ្នូរ និងដោះស្រាយនូវផលប៉ះពាល់អវិជ្ជមានផ្នែកសេដ្ឋកិច្ច និងសង្គមដោយសារតែជំងឺកូវីដ ១៩ (Covid-19) ។

យើងខ្ញុំ ដឹងថាលោក/លោកស្រី និង រដ្ឋាភិបាលនៃប្រទេសរបស់លោក/លោកស្រី កំពុងតែប្រឈមមុខក្នុងការដោះស្រាយបញ្ហាប៉ះពាល់សង្គម និងសេដ្ឋកិច្ចដោយសារតែជំងឺកូវីដ ១៩ (Covid-19) នៅក្នុងប្រទេសរបស់លោក/លោកស្រី ។ ទោះបីជាយ៉ាងនេះក្តី មត្តុទេសភាព និងការបន្តគាំទ្រចំពោះប្រជាជនដែលមានជីវភាព ក្រីក្រ និងក្រុមជនងាយរងគ្រោះបំផុតកម្ពុជា ដែលក្នុងនោះរួមមាន ជនមានពិការភាព ស្ត្រី និងកុមារ និងជាពិសេសអ្នកដែលប៉ះពាល់ដោយផ្ទាល់ពីវិបត្តិជំងឺកូវីដ ១៩ (Covid-19) ពេលបច្ចុប្បន្នគឺមានសារៈសំខាន់ខ្លាំងណាស់ ។

យើងខ្ញុំ សូមធានាដល់លោក/លោកស្រីថា យើងខ្ញុំបានត្រៀមខ្លួន រួចរាល់ដើម្បីធ្វើការជាមួយលោក/លោកស្រីក្នុងភាពជាដៃគូប្រកបដោយបរិយាប័ន្ន ដោយគាំទ្រ និង សហប្រតិបត្តិការពេញលេញ ឆ្លើយតបនឹងវិធានការជាសកលក្នុងការគ្រប់គ្រងជំងឺកូវីដ ១៩ (Covid-19) និងផលប៉ះពាល់ជាសារវ័ន្តនានា ។

សូមទទួលការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ថ្ងៃ ១៤រោច ខែ ពិសាខ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០២០
**នាយកប្រតិបត្តិ អង្គការ គ.ស.ក**

**លោក សឿង សារឿន**